ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសសាស្ត្រាចារ្យសាលាភូមិន្ទរដ្ឋបាល

សាលាភូមិន្ទរដ្ឋបាលសូមជូនដំណឹង ដល់សាស្ត្រាចារ្យទាំងពីរភេទឱ្យបានជ្រាបថា សាលាភូមិន្ទរដ្ឋបាលនឹងរៀបចំជ្រើសរើសសាស្ត្រាចារ្យពេញម៉ោង សម្រាប់បម្រើការងារនៅសាលាភូមិន្ទរដ្ឋបាលចំនួន ១០នាក់។

## I. លក្ខខណ្ឌនៃការជ្រើសរើស

ជ្រើសរើសក្នុងចំណោមបេក្ខជនទាំងពីរភេទដែលបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ដែលមានឯកទេស៖ រដ្ឋបាលសាធារណៈ គោលនយោបាយសាធារណៈ ការគ្រប់គ្រង សេដ្ឋកិច្ច គណនេយ្យ ហិរញ្ញវត្ថុសាធារណៈ សេដ្ឋកិច្ចនយោបាយ ទំនាក់ទំនងអន្តរជាតិ ការទូត និងមុខវិជ្ជាប្រហាក់ប្រហែល ពាក់ព័ន្ធនិងមុខវិជ្ជាដែលជាតម្រូវការរបស់សាលាភូមិន្ទរដ្ឋបាល

២. បទពិសោធន៍ការងារ ក្នុងវិស័យជំនាញ ឬវិស័យរដ្ឋបាលសាធារណៈ យ៉ាងតិច១០ឆ្នាំ

៣. បទពិសោធន៍ក្នុងការបង្រៀនយ៉ាងតិច៥ឆ្នាំ នៅតាមសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំឧត្តមសិក្សា

៤. ចំណេះដឹងផ្នែកព័ត៌មានវិទ្យា សម្រាប់ការងារស្រាវជ្រាវ

៥. ចំណេះដឹងភាសាអង់គ្លេស ឬភាសាបារាំង

៦. បេក្ខនារីត្រូវទទួលបានការលើកទឹកចិត្ត

## II. សំណុំលិខិតរបស់បេក្ខជន

បេក្ខជនត្រូវដាក់ពាក្យសុំបំពេញការងារ (Cover letter) ដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេប (CV) និងឯកសារពាក់ព័ន្ធនានា។ បេក្ខជនអាចមានឱកាសទទួលបានក្របខណ្ឌជាមន្ត្រីរាជការ និងទទួលកម្រៃសេវាបង្រៀនសមរម្យស្របនឹងទីផ្សារ និងមានលក្ខណៈប្រកួតប្រជែង។

## III. ការជ្រើសរើស

ពាក្យសុំបំពេញការងារចាប់ទទួលចាប់ពីថ្ងៃប្រកាសផ្សាយដំណឹងតទៅ ហូតដល់**ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង ១៧:០០នាទី រសៀល** ជាកាលកំណត់។ សាលាភូមិន្ទរដ្ឋបាលនឹងធ្វើការទាក់ទងដោយផ្ទាល់ ជាមួយបេក្ខជនដែលត្រូវបានជ្រើសរើស សម្រាប់ការសម្ភាសន៍។

ចំពោះព័ត៌មានលម្អិតបន្ថែមផ្សេងៗ បេក្ខជនអាចទាក់ទងផ្ទាល់ជាមួយផ្នែករដ្ឋបាល នៃសាលាភូមិន្ទរដ្ឋបាល ឬតាមរយៈទូរស័ព្ទលេខ ០២៣ ៦២២២២៦៦ នៅរៀងរាល់ពេលម៉ោងធ្វើការ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧

សាលាភូមិន្ទរដ្ឋបាល